# ក្បួនច្បាប់នៃការសរសេរ របស់កម្មវិធីសហព័ន្ធ WIDA * ថ្នាក់ទី១ ដល់ ថ្នាក់ទី១២
## Writing Rubric of the WIDA Consortium* Grades 1-12

| កម្រិត | កម្រិតនៃការប្រើ ភាសា វាក្យសព្ទ ដែលស្មុគស្មាញ/Linguistic Complexity Vocabulary Usage Language Control |
|---|---|
| **ទី៦ ដល់កម្រិត/**<br>**6 Reaching** | ប្រយោគដែលមានប្រវែងខុសៗគ្នា នៃលក្ខណៈស្មុគស្មាញផ្សេងៗរបស់ភាសា នៅក្នុងវគ្គដែលបានរៀបចំយ៉ាងហ្មត់ចត់ ឬនៅក្នុងអត្ថបទវែងដែលបានរៀបចំយ៉ាងល្អ មានខ្លឹមសារ និងមានការរៀបចំច្បាស់លាស់។<br><br>ការប្រើប្រាស់ពាក្យត្រូវតាមកាលៈទេសៈ។ ការប្រើវាក្យសព្ទជាទូទៅ ច្បាស់លាស់ ចំៗ ឬ ភាសាបច្ចេកទេស។<br><br>បានឈានដល់ភាពប្រហាក់ប្រហែលនឹងមិត្តភ័ក្តដែលចេះភាសាអង់គ្លេសស្ទាត់ជំនាញ ក្នុងកម្រិត «ស្ទាត់ជំនាញ» ក្នុងការប្រឡងទូទាំងរដ្ឋ។ |
| **ទី៥ តន្ទាប់/**<br>**5 Bridging** | ប្រយោគដែលមានប្រវែងខុសៗគ្នា នៃលក្ខណៈស្មុគស្មាញផ្សេងៗរបស់ភាសា នៅក្នុងវគ្គដែលបានរៀបចំយ៉ាងហ្មត់ចត់ ឬនៅក្នុងអត្ថបទវែង មានខ្លឹមសារ និងមានការរៀបចំច្បាស់លាស់។<br><br>ការប្រើភាសាបច្ចេកទេស ដែលទាក់ទងនឹងមុខវិទ្យា។ បង្ហាញសមត្ថភាពនៃការប្រើវាក្យស័ព្ទដែលត្រូវការ។<br><br>ឈានដល់ការប្រៀបធៀបទៅនឹងមិត្តភ័ក្តដែលចេះភាសាអង់គ្លេសស្ទាត់ជំនាញ។ កំហុសទាំងឡាយមិនមែនជាឧបស័គ្គដែលមិនអាចឲ្យយល់បាននោះទេ។ |
| **ទី៤ រីកដុះដាល/**<br>**4 Expanding** | ប្រយោគដែលមានប្រវែងខុសៗគ្នា នៃលក្ខណៈស្មុគស្មាញផ្សេងៗរបស់ភាសា។ ចាប់ផ្តើមប្រើពាក្យ ដើម្បីផ្តល់នូវ ព័ត៌មានលម្អិត និងភាពច្បាស់លាស់។<br><br>ការប្រើប្រាស់នៃភាសាចំៗ និងភាសាបច្ចេកទេសខ្លះៗ ដែលទាក់ទងនឹងមុខវិទ្យា។ ម្តងម្កាលបង្ហាញឲ្យឃើញថាមានការខ្វះខាតវាក្យសព្ទដែលត្រូវការ។<br><br>ជាទូទៅ អាចឲ្យយល់បានគ្រប់ពេលវេលា កំហុសទាំងឡាយមិនមែនជាឧបស័គ្គរារាំងមិនឲ្យយល់អត្ថន័យទូទៅទេ។ កំហុសទាំងឡាយអាចឆ្លុះបញ្ចាំងពីការជ្រៀតជ្រែកនៃភាសាកំណើត។ |
| **ទី៣ អភិវឌ្ឍន៍/**<br>**3 Developing** | ប្រយោគងាយស្រួល និងវែងៗ ដែលបង្ហាញឲ្យឃើញនូវការចាប់ផ្តើមនៃការប្រើពាក្យពិបាកៗ ដើម្បីផ្តល់ព័ត៌មានលម្អិត។<br><br>ការប្រើប្រាស់ភាសាទូទៅ និងពាក្យចំៗមួយចំនួន ដែលទាក់ទងនឹងមុខវិទ្យា។ បង្ហាញឲ្យឃើញថាមានការខ្វះខាតវាក្យសព្ទដែលត្រូវការ។<br><br>ជាទូទៅ អាចយល់បាននៅពេលសរសេរឃ្លាប្រយោគ។ ពេលខ្លះកំហុសអាចជាឧបស័គ្គរារាំងមិនអាចឲ្យយល់បាន នៅពេលព្យាយាមសរសេរអត្ថបទដែលមានលក្ខណៈស្មុគស្មាញ។ |
| **ទី២ ចាប់ផ្តើម/**<br>**2 Beginning** | ឃ្លា និង ប្រយោគខ្លីៗ។ អត្ថបទដែលមានប្រវែងខុសៗគ្នាមួយចំនួន អាចចម្លង ឬយកលំនាំតាម។ អាចបង្ហាញឲ្យឃើញមានការព្យាយាមរៀបចំខ្លះ។<br><br>ការប្រើប្រាស់ភាសាទូទៅ ដែលទាក់ទងនឹងមុខវិទ្យា។ បង្ហាញឲ្យឃើញមានការខ្វះខាតវាក្យសព្ទ។<br><br>ជាទូទៅ អាចឲ្យយល់បាននៅពេលយកលំនាំពី គំរូ ឬ ប្រភព នៃអត្ថបទ ឬនៅពេលដែលអត្ថបទដើមជាប្រភេទអត្ថបទសាមញ្ញ។ កំហុសតែងតែជាឧបស័គ្គរារាំងមិនអាចឲ្យយល់បាន។ |
| **ទី១ ចូលដំបូង/**<br>**1 Entering** | ពាក្យមួយម៉ាត់ៗ ឃ្លាមួយក្រុមៗ ឬភាសាសាមញ្ញមួយចំនួន។ អត្ថបទដែលមានប្រវែងខុសៗគ្នាមួយចំនួន អាចចម្លង ឬយកលំនាំតាម។ យកលំនាំតាមអត្ថបទនៃភាសាដើម។<br><br>ការប្រើវាក្យសព្ទដែលគេឧស្សាហ៍ប្រើពីសាលារៀន និង ពីមុខវិទ្យា។<br><br>ជាទូទៅ អាចឲ្យយល់បាននៅពេលយកលំនាំពី គំរូ ឬ ប្រភព នៃអត្ថបទ។ អត្ថបទដើមអាចជាឧបស័គ្គរារាំងមិនអាចឲ្យយល់បាន។ |

*សម្រាប់ប្រើជាមួយការប្រឡង ACCESS for ELLs®, the W-APT, និងការវាយតម្លៃ ការអប់រំ/ថ្នាក់រៀន ក្នុងរដ្ឋដែលធ្វើតាម WIDA។

© WIDA 2007